ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ៣៣០ ព.ណ.ស.ជ.ប្រក

# ប្រកាស
# ស្តីពី
# ការកំណត់នីតិវិធីអនុវត្ត
# ប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០១៤ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្តប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន (ASEAN-Wide Self Certification -AWSC) ក្នុងគោលបំណងសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងតំបន់អាស៊ាន។

**ប្រការ២.-**

ដើម្បីចូលរួមអនុវត្តប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន នាយកដ្ឋាននាំចេញ នាំចូល នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ត្រូវមានភារកិច្ចដូចខាងក្រោម៖



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- ចុះត្រួតពិនិត្យវាយតម្លៃអនុលោមតាមលក្ខខណ្ឌ ស្តីពីការធ្វើប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញនៅមូលដ្ឋាន ផលិតកម្ម ឬទីតាំងស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
- ផ្តល់នីតិសម្បទាជូនផលិតករ ឬអ្នកនាំចេញ ជាអ្នកនាំចេញដែលមានការទទួលស្គាល់ (Certified Exporter-CE) ដើម្បីទទួលបានសិទ្ធិក្នុងការអនុវត្តប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញ
- បញ្ចូលព័ត៌មានអ្នកនាំចេញ ដែលមានការទទួលស្គាល់ក្នុងប្រព័ន្ធទិន្នន័យស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន (AWSC CE Database) បន្ទាប់ពីបានផ្តល់នីតិសម្បទាជូនផលិតករ ឬអ្នកនាំចេញ ជាអ្នកនាំចេញដែលមានការទទួលស្គាល់
- ចុះត្រួតពិនិត្យមុននាំចេញទំនិញតាមការស្នើសុំរបស់ផលិតករ និង/ឬអ្នកនាំចេញ ឬអ្នកតំណាងដែលទទួលបានសិទ្ធិ ដើម្បីកំណត់ដើមកំណើតទំនិញដែលត្រូវនាំចេញនៅពេលបន្ទាប់ ដោយអាស្រ័យលើការពិនិត្យឡើងវិញជាប្រចាំ ឬនៅពេលសមស្របណាមួយ។

**ប្រការ៣.-**

ផលិតករ ឬអ្នកនាំចេញ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ជាផលិតករ ឬអ្នកនាំចេញ ដែលមានមូលដ្ឋានផលិតកម្ម ឬទីតាំងស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
- ត្រូវបានចុះបញ្ជីស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- ត្រូវមានចំណេះដឹងអំពីវិធានដើមកំណើតដូចមានចែងក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន
- ត្រូវមានចំណេះដឹងអាចប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក
- មិនត្រូវមានកំណត់ត្រាក្លែងបន្លំនៃវិធានដើមកំណើតណាមួយឡើយ ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- មិនស្ថិតក្រោមការឃ្លាំមើល ឬស្ថិតក្នុងបញ្ជីខ្មៅរបស់ស្ថាប័នមានសមត្ថកិច្ច
- ធ្លាប់មានបទពិសោធន៍ក្នុងការប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្នុងការនាំចេញទំនិញ
- ត្រូវអនុវត្តតាមវិធានការនៃការគ្រប់គ្រងហានិភ័យរបស់អាជ្ញាធរមានសមត្ថកិច្ច
- អ្នកនាំចេញត្រូវមានប្រព័ន្ធរក្សាកំណត់ត្រា និងបញ្ជីគណនេយ្យមួយឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៤.-**

ផលិតករ ឬអ្នកនាំចេញ ដែលមានបំណងទទួលបានសិទ្ធិអនុវត្តប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញត្រូវដាក់ពាក្យស្នើសុំដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- ពាក្យស្នើសុំ (តាមគំរូមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ១) ឬអាចទាញយកពីគេហទំព័រប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញរបស់ក្រសួងពាណិជ្ជកម្ម (https://co.moc.gov.kh)
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងវិញ្ញាបនបត្រចុះបញ្ជីសុំសិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងពាណិជ្ជកម្មសេរី (ច្បាប់ថតចម្លង)
- ប័ណ្ណប៉ាតង់ (ច្បាប់ថតចម្លង)

- លិខិតអនុញ្ញាតពីស្ថាប័នពាក់ព័ន្ធ ក្នុងករណីទំនិញជាប់កម្រិតកំណត់ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់របស់រាជរដ្ឋាភិបាលដែលស្ថិតនៅជាធរមាន
- តារាងលម្អិតថ្លៃដើម ឬឯកសារអំណះអំណាងបញ្ជាក់ដើមកំណើតទំនិញនាំចេញ
- លិខិតប្រគល់សិទ្ធិ គំរូហត្ថលេខា និងត្រារបស់ក្រុមហ៊ុន (អ្នកមានសិទ្ធិចុះហត្ថលេខាមិនឱ្យលើសពី ១០នាក់)
- របាយការណ៍វាយតម្លៃអនុលោមភាពស្តីពីការធ្វើប្រតិវេទន៍ដើមកំណើតទំនិញក្នុងក្របខណ្ឌអាស៊ាន
- ឯកសារផ្សេងៗតាមការចាំបាច់។

**ប្រការ៥.-**

បន្ទាប់ពីទទួលបាននីតិសម្បទា អ្នកនាំចេញដែលមានការទទួលស្គាល់ (CE) ត្រូវ៖

- ស្នើសុំទៅនាយកដ្ឋាននាំចេញ នាំចូល នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ដើម្បីត្រួតពិនិត្យមុននាំចេញលើដើមកំណើតទំនិញ ដែលត្រូវនាំចេញនៅពេលបន្ទាប់ (ការស្នើសុំត្រួតពិនិត្យមុនពេលនាំចេញអាចនឹងមិនត្រូវបានអនុវត្ត ចំពោះទំនិញណាដែលដើមកំណើតអាចត្រូវបានកំណត់យ៉ាងងាយស្រួល ដោយលក្ខណៈធម្មជាតិរបស់ទំនិញ)
- អនុញ្ញាតឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះត្រួតពិនិត្យដល់ទីតាំងផលិត ដើម្បីតាមដានការអនុវត្ត និងការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃប្រតិវេទន៍ដែលបានធ្វើឡើង (កំណត់ត្រា និងគណនីទាំងនោះត្រូវអនុញ្ញាតសម្រាប់ការធ្វើលក្ខណៈវិនិច្ឆ័យ និងការពិនិត្យផ្ទៀងផ្ទាត់ពីដើមកំណើតទំនិញ នៅពេលដែលប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញមួយត្រូវបានធ្វើឡើងក្នុងរយៈពេលយ៉ាងតិច ៣(បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចេញប្រតិវេទន៍ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន)
- ចេញប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញ ចំពោះទំនិញដែលទទួលបានសិទ្ធិឱ្យធ្វើប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញ និងមានឯកសារអំណះអំណាងដើមកំណើតទំនិញ
- ទទួលខុសត្រូវទាំងស្រុងចំពោះប្រតិវេទន៍ស្វ័យបញ្ជាក់ដើមដំណើតទំនិញរបស់ខ្លួន និងការប្រើប្រាស់មិនត្រឹមត្រូវផ្សេងទៀត
- ជូនដំណឹងជាបន្ទាន់មកនាយកដ្ឋាននាំចេញ នាំចូល នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នូវរាល់ការផ្លាស់ប្តូរដែលទាក់ទងនឹងព័ត៌មានដែលបានស្នើសុំ
- ផ្តល់របាយការណ៍មកនាយកដ្ឋាននាំចេញ នាំចូល នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម (តាមគំរូមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ២) តាមគេហទំព័រប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញរបស់ក្រសួងពាណិជ្ជកម្ម (https://co.moc.gov.kh) បន្ទាប់ពីចេញទំនិញតាមប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញមិនឱ្យលើសពី ៣០(សាមសិប) ថ្ងៃ ក្រោយការនាំចេញ ស្របតាមបទប្បញ្ញត្តិនានាដែលស្ថិតនៅជាធរមាន
- ត្រៀមខ្លួនជាស្រេច ដើម្បីសហការក្នុងការត្រួតពិនិត្យជាលក្ខណៈប្រតិសកម្ម និងទស្សនកិច្ចផ្ទៀងផ្ទាត់ប្រសិនបើចាំបាច់
- ក្នុងករណីដែលអ្នកនាំចេញជា "ពាណិជ្ជករ" អ្នកនាំចេញនោះត្រូវមាន "ប្រតិវេទន៍របស់អ្នកផលិត" ដែលបង្ហាញពីដើមកំណើតនៃផលិតផលក្នុងការធ្វើស្វ័យបញ្ជាក់
- ផលិតករ ឬអ្នកនាំចេញ ត្រូវបំពេញកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈ និងកម្រៃនានាតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ៦.-**

សុពលភាពនៃការអនុវត្តប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញមានរយៈពេល ២(ពីរ)ឆ្នាំ។ ក្រុមហ៊ុនត្រូវមកស្នើសុំបន្តសុពលភាពឡើងវិញរយៈពេល ៣០ (សាមសិប)ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាព។

**ប្រការ៧.-**

ក្រសួងពាណិជ្ជកម្ម អាចដកហូតសិទ្ធិ ក្នុងករណីអ្នកនាំចេញដែលមានការទទួលស្គាល់ មិនអនុវត្តស្របតាមខ្លឹមសារដែលមានចែងក្នុងប្រការ៥។ ការដកហូតសិទ្ធិនឹងត្រូវធ្វើឡើង តាមរយៈសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**ប្រការ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន គ្រប់តំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស គ្រប់ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- សមាគមស្បែកជើងកម្ពុជា
- សហព័ន្ធស្រូវអង្ករកម្ពុជា
- ដូចប្រការ៩
- ឯកសារ កាលប្បវត្តិ